**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកសិកម្ម**

លេខ......១៦៣៣......អ.ន.ក

ថ្ងៃ.....................ខែ.....................ឆ្នាំ.....................ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី.....៣០.....ខែ.....សីហា.....ឆ្នាំ២០១៩

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** : របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែសីហា ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសិកម្ម។

**ជូនភ្ជាប់** : របាយការណ៍លម្អិតស្តីពី សកម្មភាពអនុវត្តការងារប្រចាំខែសីហា ឆ្នាំ២០១៩ " គិតត្រឹមថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ " ចំនួន ......... .........០១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា សកម្មភាពអនុវត្តការងារប្រចាំខែសីហា ឆ្នាំ២០១៩ "គិតត្រឹមថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ " សម្រេចបានដូចខាងក្រោម:

ក. ដំណាំស្រូវ : ស្ទូង និងព្រោះអនុវត្តបានចំនួន ២ ៤៨០ ៥៥៩ ហ.ត ស្មើនឹង ៩៥,៩២ % នៃផែនការចំនួន ២ ៥៨៦ ១៥២ ហ.ត យឺតជាងឆ្នាំមុន ៩៤ ៥២៣ ហ.ត

បច្ចុប្បន្នកសិករ បាននិងកំពុងប្រមូលផលស្រូវដើមរដូវវស្សាលើផ្ទៃដីចំនួន ១៦៧ ៧៧១ ហ.ត ស្មើនឹង៦,៧៦% នៃផ្ទៃដីអនុវត្ត ដោយទទួលបានទិន្នផលជាមធ្យម ៤,២១២ ត/ហ.ត និងបរិមាណផល ៧០៦ ៦៥៧ តោន។

ខ. ដំណាំរួមផ្សំ : អនុវត្តបាន ៤៦ ៦៨៨ ហ.ត លឿនជាងឆ្នាំមុន ១ ៥៥១ ហ.ត

គ. ដំណាំឧស្សាហកម្ម : អនុវត្តបាន ៧៦៥ ១៥៥ ហ.ត យឺតជាងឆ្នាំមុន ៧៣ ៥៥៨ ហ.ត

**ឃ.ការនាំចេញកសិផលផ្លូវការ:** ក្នុងខែសីហានេះ អគ្គនាយកដ្ឋានកសិកម្ម បានផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ផលិតផលនាំចេញចំនួន ៣០០ ៩៥២ តោន (គិតត្រឹមថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩)។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក**

**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ងិន ឆាយ**

**ចម្លងជូន ៖**

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តមអគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីគោរពជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានកសិកម្ម
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427